**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧ ១-០៨-០០២ ...

លិខិតចូល
ថ្ងៃទី១២ ខែមិថុនា ឆ្នាំ2008

## បទបញ្ជាផ្ទៃក្នុង
## នៃ
## ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៅកម្ពុជា

- យោងតាមច្បាប់ស្តីពី "ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម" ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧
- យោងអនុក្រឹត្យស្តីពី "ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ" លេខ១០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០០៨
- យោងស្មារតីអង្គប្រជុំក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាលើកទី១ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨ បានអនុម័តបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលមានខ្លឹមសារដូចខាងក្រោមនេះ :

### ជំពូកទី ១
### លេខាធិការដ្ឋាន

**ប្រការ១.-** លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានបុគ្គលិកគ្រប់គ្រាន់ដែលត្រូវជ្រើសរើសដោយប្រធាន និងត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។ បុគ្គលិកត្រូវមានលក្ខណៈសម្បត្តិសុចរិតកម្រិតខ្ពស់ និងត្រូវបានពិនិត្យជ្រើសរើសដោយអាជ្ញាធរពាក់ព័ន្ធមុននឹងត្រូវបានអនុញ្ញាតឱ្យបម្រើការនៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

**ប្រការ២.-** ប្រធានក្រុមប្រឹក្សាភិបាល អាចកោះអញ្ជើញមន្ត្រីរបស់ស្ថាប័នដទៃទៀតឱ្យចូលរួមក្នុងអង្គប្រជុំ ដើម្បីជួយបំភ្លឺការងារជំនាញ ។

**ប្រការ៣.-** កំណត់ហេតុ និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សាភិបាល ត្រូវរក្សាទុកនៅលេខាធិការដ្ឋាន ហើយមិនត្រូវធ្វើឱ្យបែកខ្ចរខ្ចាយទៅខាងក្រៅដោយគ្មានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាភិបាលឡើយ ។

## ជំពូកទី ២
## ការប្រជុំ

**ប្រការ៤.**- ក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំយ៉ាងហោចណាស់បីខែម្តង ក្នុងមួយឆ្នាំ ។ ប្រធានក្រុមប្រឹក្សាភិបាលមានសិទ្ធិកោះប្រជុំនៅពេលមានការចាំបាច់ ។

**ប្រការ៥.**- ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះអញ្ជើញសមាជិកនៃក្រុមប្រឹក្សាភិបាលដើម្បីចូលរួមប្រជុំ ក្នុងរយៈពេលយ៉ាងហោចណាស់ ៥ថ្ងៃធ្វើការមុនការប្រជុំ ដោយមានបញ្ជាក់ពីរបៀបវារៈ កាលបរិច្ឆេទ និងទីកន្លែងប្រជុំ ។

**ប្រការ៦.**- លិខិតអញ្ជើញដែលបានបញ្ជូនទៅសមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានហត្ថលេខាទទួលពីតំណាងសាមីស្ថាប័ន ។

**ប្រការ៧.**- ឯកសារទាក់ទងនឹងខ្លឹមសារនៃអង្គប្រជុំនីមួយៗ ត្រូវបញ្ជូនទៅសមាជិកក្រុមប្រឹក្សាភិបាល ឱ្យបានមុនកាលបរិច្ឆេទប្រជុំ លើកលែងតែឯកសារដែលមានលក្ខណៈបន្ទាន់ ។

**ប្រការ៨.**- រាល់ពេលប្រជុំត្រូវមានបញ្ជីវត្តមាន និងហត្ថលេខារបស់សមាជិកអង្គប្រជុំ ។

**ប្រការ៩.**- អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាជិកចូលប្រជុំចាប់ពី ៣នាក់ឡើងទៅ ហើយត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ។ ក្នុងករណីអវត្តមានរបស់ប្រធានក្រុមប្រឹក្សាភិបាល ការប្រជុំត្រូវលើកទៅពេលក្រោយ ។ ក្នុងករណីមិនគ្រប់កូរ៉ុម ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះអញ្ជើញជាថ្មី ដោយរក្សារបៀបវារៈដដែល ។ ប្រធានក្រុមប្រឹក្សាភិបាលកំណត់កាលបរិច្ឆេទប្រជុំលើកទី២ នេះ ហើយអង្គប្រជុំអាចសម្រេចការងារ ដោយមិនគិតពីកូរ៉ុមទេ ។

**ប្រការ១០.**- អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលពិភាក្សាជាចំហលើខ្លឹមសារនៃរបៀបវារៈនីមួយៗ ហើយអនុម័តដោយវិធីលើកដៃ ។

**ប្រការ១១.**- អង្គប្រជុំត្រូវសម្រេចដោយសម្លេងភាគច្រើននៃសមាជិកវត្តមានក្នុងអង្គប្រជុំ ។ ក្នុងករណីសម្លេងស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាភិបាលត្រូវមានឧត្តមានុភាព ។

**ប្រការ១២.**- នៅពេលប្រជុំម្តងៗ លេខាធិការដ្ឋានត្រូវធ្វើកំណត់ហេតុនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានច្បាស់លាស់ ហើយត្រូវដាក់ជូនសមាជិកក្រុមប្រឹក្សាភិបាលពិនិត្យជាមុន និងចុះហត្ថលេខានៅកិច្ចប្រជុំលើកក្រោយ ។

**ប្រការ១៣.**- ក្រោយពេលប្រជុំនីមួយៗ ប្រធានក្រុមប្រឹក្សាភិបាលត្រូវចេញសេចក្តីជូនដំណឹងជាបន្ទាន់ អំពីលទ្ធផលនៃការប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីជាមូលដ្ឋានសម្រាប់យកទៅអនុវត្តឱ្យមានប្រសិទ្ធភាព ។/.

## ជំពូកទី ៣

## តម្លៃការ

**ប្រការ១៤.-** សមាជិកក្រុមប្រឹក្សាភិបាល ត្រូវទទួលកម្រៃវត្តមាននៃអង្គប្រជុំមួយលើកៗ តាមការកំណត់របស់អង្គប្រជុំក្រុមប្រឹក្សាភិបាល ។

**ប្រការ១៥.-** លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាល និងមន្ត្រីជំនាញដែលចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ត្រូវទទួលកម្រៃលើកទឹកចិត្ត តាមការកំណត់របស់ក្រុមប្រឹក្សាភិបាល ។

## ជំពូកទី៤

## ថវិកា

**ប្រការ១៦.-** ថវិការបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU) មានប្រភពមកពី :

- អំណោយឧបត្ថម្ភពីស្ថាប័នក្នុង និងក្រៅប្រទេស
- ធនាគារជាតិនៃកម្ពុជា

**ប្រការ១៧.-** រាល់ការចំណាយសម្រាប់ប្រតិបត្តិការបម្រើប្រយោជន៍ឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ជាបន្ទុកចំណាយរបស់ធនាគារជាតិនៃកម្ពុជា ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ១៨.-** ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបញ្ញត្តិផ្សេងៗនៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ១៩.-** បទបញ្ជាផ្ទៃក្នុងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៨

ប្រធានក្រុមប្រឹក្សាភិបាល

ជា-ចាន់តូ

កន្លែងទទួល

- សមាជិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"